64

ព្រះរាជក្រឹត្យ

នស/រកត/០៦០២/១៦៥

ស្តីពី

លក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលបឋម

ក្រសួងសុខាភិបាល
អគ្គលេខាធិការដ្ឋាន
ទទួលថ្ងៃទី ១៩ ខែ ០៧ ឆ្នាំ ២០០២ ម៉ោង ..... នាទី
ចុះក្នុងលេខ 420

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី ដោយមានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២

# ត្រាស់បង្គាប់

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

ត្រូវបានបង្កើតក្របខ័ណ្ឌមន្ត្រីសុខាភិបាលបឋមរបស់ក្រសួងសុខាភិបាល ដែលត្រូវចាត់ថ្នាក់ក្នុងប្រភេទ "គ" ដូចមានចែងក្នុងមាត្រា៥ នៃព្រះរាជក្រឹត្យ លេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ ។

មាត្រា ២.-

ក្របខ័ណ្ឌមន្ត្រីសុខាភិបាលបឋម ស្ថិតនៅក្រោមឱវាទក្រសួងសុខាភិបាល ប្រមូលផ្តុំមន្ត្រីបច្ចេកទេសសុខាភិបាលកំរិតបឋម បំរើការងារក្នុងវិស័យសុខាភិបាល តាមអង្គភាពជំនាញថ្នាក់កណ្តាល និង ខេត្ត ក្រុង និង គ្រឹះស្ថានសាធារណៈ របស់ក្រសួង ស្ថាប័នរដ្ឋ ។

មាត្រា ៣.-

មន្ត្រីនៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលបឋម មានមុខងារក្នុងការប្រតិបត្តិបច្ចេកទេសជំនាញ សុខាភិបាល ។

## ជំពូកទី ២

## ឋានន្តរស័ក្តិ និង ថ្នាក់ដំណែង

មាត្រា ៤.-

ក្របខ័ណ្ឌ មន្ត្រីសុខាភិបាលបឋម មាន ៣ ឋានន្តរស័ក្តិ :

- ឋានន្តរស័ក្តិទី ១ ឬ ឋានន្តរស័ក្តិ មន្ត្រីសុខាភិបាលបឋម ដើមខ្សែពិសេសមាន ៦ ថ្នាក់
- ឋានន្តរស័ក្តិទី ២ ឬ ឋានន្តរស័ក្តិ មន្ត្រីសុខាភិបាលបឋម ដើមខ្សែមាន ១០ ថ្នាក់
- ឋានន្តរស័ក្តិទី ៣ ឬ ឋានន្តរស័ក្តិ មន្ត្រីសុខាភិបាលបឋមមាន ១៤ ថ្នាក់ ។ល។

# ជំពូកទី ៣
## ការជ្រើសរើស

**មាត្រា ៥.-**

ការជ្រើសរើសអោយចូលក្នុងក្របខ័ណ្ឌមន្ត្រីសុខាភិបាលបឋម ត្រូវធ្វើឡើងតាមការប្រលងជ្រើសរើស ក្នុងចំណោមបេក្ខជនជាសិស្ស និស្សិត និងឬ ជាមន្ត្រីរាជការ ។ ចំនួនតំណែងក្នុងការជ្រើសរើស សំរាប់បេក្ខជនជាសិស្ស និស្សិត និង ជាមន្ត្រីរាជការតាមផ្នែកនីមួយៗត្រូវកំណត់ឡើងដោយរាជរដ្ឋាភិបាល តាមសំណើរបស់ក្រសួងសុខាភិបាល ។

**មាត្រា ៦.-**

ការប្រលងជ្រើសរើសចូលក្របខ័ណ្ឌ ក្នុងចំណោមនិស្សិត ត្រូវបើកទូលាយចំពោះបេក្ខជនដែលមានអាយុច្រើនបំផុត ២៥ ឆ្នាំ គិតមកដល់ថ្ងៃប្រលង ហើយដែលមានសញ្ញាប័ត្រផ្នែកណាមួយ យ៉ាងទាប ដូចខាងក្រោម :

- សញ្ញាប័ត្រ គិលានុបដ្ឋាក គិលានុបដ្ឋាយិកាបឋម
- សញ្ញាប័ត្រឆ្មបបឋម
- សញ្ញាប័ត្រអ្នកបច្ចេកទេសមន្ទីរពិសោធន៍បឋម

និងសញ្ញាប័ត្រជំនាញ ផ្នែកបច្ចេកទេសថែទាំនិងអមវេជ្ជសាស្ត្រឯទៀត ដែលមានតំលៃស្មើនឹងសញ្ញាប័ត្រខាងលើ ។

ចំពោះមន្ត្រី ដែលមានសញ្ញាប័ត្រដូចខាងលើ អាចប្រលងចូលក្របខ័ណ្ឌនេះបាន ដោយពុំគិតពីល័ក្ខខ័ណ្ឌនៃឋានន្តរស័ក្តិ និងប្រភេទក្របខ័ណ្ឌឡើយ ហើយមានអាយុច្រើនបំផុត ៣៥ ឆ្នាំ ។

# ជំពូកទី ៤
## ការបណ្តុះបណ្តាលដំបូង កម្មសិក្សាសាកល្បង និង ការតាំងស៊ប់

**មាត្រា ៧.-**

បេក្ខជន ដែលបានជ្រើសរើសតាមរយៈការប្រលងជ្រើសរើស ត្រូវទទួលការបណ្តុះបណ្តាលដំបូងរៀបចំឡើងដោយក្រសួងសុខាភិបាល ហើយមានឋានៈជានិស្សិតមន្ត្រីសុខាភិបាលបឋម ។

**មាត្រា ៨.-**

បន្ទាប់ពីការបណ្តុះបណ្តាលដំបូង និស្សិតមន្ត្រីសុខាភិបាលបឋម ត្រូវចាត់អោយទៅបំរើការងារនៅតាមអង្គភាពសុខាភិបាល ខេត្ត ក្រុង និងថ្នាក់កណ្តាល ដោយផ្អែកលើលទ្ធផលនៃការបណ្តុះបណ្តាល ហើយត្រូវ តែងតាំងជាមន្ត្រីសុខាភិបាលបឋមកម្មសិក្សាដោយប្រកាសរបស់ក្រសួងសុខាភិបាល ។

មន្ត្រីសុខាភិបាលបឋម ដែលជ្រើសរើសចេញពីសិស្ស និស្សិត ត្រូវឆ្លងកាត់កម្មសិក្សារយៈពេល ១២ ខែ ។ ក្រោយពេលបញ្ចប់កម្មសិក្សាសាកល្បងដោយជោគជ័យ មន្ត្រីទាំងនេះត្រូវបានតាំងស៊ប់ក្នុងថ្នាក់លេខ ១៤ នៃឋានន្តរស័ក្តិទី៣ ។

មន្ត្រីសុខាភិបាលបឋម ដែលជ្រើសរើសចេញពីមន្ត្រីរាជការ ត្រូវធ្វើកម្មសិក្សាសាកល្បងរយៈពេល ០៦ ខែ ។/.

មន្ត្រីសុខាភិបាលបឋម ដែលបានជ្រើសរើសតាមការប្រឡងប្រជែងក្នុងចំណោមមន្ត្រីរាជការ ត្រូវបញ្ចូលទៅក្នុងឋានន្តរស័ក្តិទី៣ ក្នុងថ្នាក់ដែលមានសន្ទស្សន៍បៀវត្សខ្ពស់ លើបន្ទាប់ពីសន្ទស្សន៍បៀវត្សចាស់របស់សាមីខ្លួន ។

មន្ត្រីសុខាភិបាលបឋម ដែលធ្វើកម្មសិក្សា មិនបានសំរេចជោគជ័យ ត្រូវអនុញ្ញាតអោយបន្តធ្វើកម្មសិក្សានៅលើកទី២ទៀត ។ ក្នុងករណីដែលមិនទទួលជោគជ័យជាលើកទី២ នេះ កម្មសិក្សាការីដែលជ្រើសរើសពីសិស្ស និស្សិតត្រូវលុបឈ្មោះចេញ កម្មសិក្សាការីដែលជ្រើសរើសពីមន្ត្រីរាជការត្រូវបញ្ជូនទៅក្របខ័ណ្ឌដើមវិញ ដោយគិតរយៈពេលបណ្តុះបណ្តាលដំបូង និងកម្មសិក្សា សំរាប់អតីតភាពការងារ ។

ការតាំងស៊ប់ក្នុងឋានន្តរស័ក្តិទី៣ នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលបឋម ត្រូវធ្វើឡើងដោយប្រកាសរបស់ក្រសួងសុខាភិបាល ។

## ជំពូកទី ៥

## ការតែងតាំង

**មាត្រា ៩.-**

ក្រោយពេលតាំងស៊ប់ក្នុងក្របខ័ណ្ឌ មន្ត្រីក្របខ័ណ្ឌមន្ត្រីសុខាភិបាលបឋម អាចត្រូវតែងតាំងក្នុងមុខតំណែងទំនេរណាមួយ ដូចមានកំណត់ក្នុងមាត្រា ៣ ខាងលើ ។

## ជំពូកទី ៦

## ការដាក់អោយស្ថិតនៅក្រៅក្របខ័ណ្ឌដើម

**មាត្រា ១០.-**

មន្ត្រីសុខាភិបាលបឋម អាចត្រូវដាក់អោយស្ថិតក្រៅក្របខ័ណ្ឌដើម ឬ ក្រៅតំណែងដើម ដើម្បីទៅបំរើការនៅតាមក្រសួង ស្ថាប័ន ឬ អង្គភាពផ្សេងណាមួយ តាមតំរូវការ និងតាមការយល់ព្រមពីសាមីជន ។

## ជំពូកទី ៧

## ការដំឡើងថ្នាក់ និង ការដំឡើងឋានន្តរស័ក្តិ

**មាត្រា ១១.-**

មន្ត្រីសុខាភិបាលបឋម ត្រូវដំឡើងថ្នាក់ក្នុងឋានន្តរស័ក្តិណាមួយ ទៅតាមល័ក្ខខ័ណ្ឌដូចបានចែងក្នុង មាត្រា ២០ និង មាត្រាបន្តបន្ទាប់ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ។

លក្ខណៈសម្បត្តិ ជាមូលដ្ឋានសំរាប់ការពិនិត្យដំឡើងថ្នាក់មានដូចខាងក្រោម :

- គំនិតផ្តួចផ្តើមច្នៃប្រឌិត និងលទ្ធផលការងារ
- ស្មារតីទទួលខុសត្រូវ វិន័យការងារ មនសិការវិជ្ជាជីវៈ
- ការយកចិត្តទុកដាក់ដល់ផលប្រយោជន៍ជាតិ
- សាមគ្គីធម៌ និង សីលធម៌រស់នៅ ។ ល។

ការដំឡើងថ្នាក់នៃអ្នករាជការក្នុងក្របខ័ណ្ឌមន្ត្រីសុខាភិបាលបឋម ត្រូវគិតក្នុងសមាមាត្រ ៣ ភាគ ៤ តាមវេនជ្រើសរើស និង ១ ភាគ ៤ តាមវេនអតីតភាព ។

**មាត្រា ១២.-**

គោលការណ៍នៃការដំឡើងឋានន្តរស័ក្តិ តាមធម្មតា ត្រូវដំឡើងទៅក្នុងថ្នាក់ដំបូងនៃឋានន្តរស័ក្តិខ្ពស់ លើបន្ទាប់ ឬក្នុងករណីចាំបាច់ត្រូវដំឡើងទៅ ក្នុងថ្នាក់ដែលមានសន្ទស្សន៍ខ្ពស់ លើបន្ទាប់ពីសន្ទស្សន៍ចាស់របស់មន្ត្រីសាមី ។

ចំនួនដំណែងក្នុងឋានន្តរស័ក្តិនីមួយៗ ត្រូវកំណត់ ដូចខាងក្រោម :

- ៥ % ជាអតិបរមា សំរាប់ឋានន្តរស័ក្តិទី១
- ២៥ % ជាអតិបរមា សំរាប់ឋានន្តរស័ក្តិទី២
- ៧០ % ឡើងទៅ សំរាប់ឋានន្តរស័ក្តិទី៣ ។

ការដំឡើងឋានន្តរស័ក្តិមន្ត្រីក្របខ័ណ្ឌមន្ត្រីសុខាភិបាលបឋម ត្រូវធ្វើតាមរយៈការចុះឈ្មោះក្នុងតារាងដំឡើងឋានន្តរស័ក្តិ និងការវាយតំលៃ របស់ឋានានុក្រមគ្រប់គ្រង ឬ តាមរយៈការបណ្តុះបណ្តាលបន្តនៅក្នុង ឬក្រៅប្រទេស។

ការដំឡើងថ្នាក់និងការដំឡើងឋានន្តរស័ក្តិនៃមន្ត្រីសុខាភិបាលបឋម ត្រូវសំរេចដោយប្រកាសរបស់ក្រសួងសុខាភិបាល ។

**មាត្រា ១៣.-**

សន្ទស្សន៍ សំរាប់ថ្នាក់ក្នុងឋានន្តរស័ក្តិនីមួយៗ នៃក្របខ័ណ្ឌ និងតំលៃឯកតានៃសន្ទស្សន៍ ត្រូវបានកំណត់ស្របតាមមាត្រា៣ និងមាត្រា៤ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាននិងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការ ។

## ជំពូកទី ៨

## បទប្បញ្ញត្តិដោយឡែក

**មាត្រា ១៤.-**

មន្ត្រីសុខាភិបាលបឋម ដែលក្រសួងចាត់អោយទៅទទួលការបំប៉ន ឬការបណ្តុះបណ្តាលបន្តរយៈពេលសរុប យ៉ាងតិច ០៦ ខែ ក្នុងជំនាញរបស់ខ្លួន ដោយមានវិញ្ញាបនប័ត្រ ឬលិខិតបញ្ជាក់ការសិក្សា ត្រូវទទួលការតំឡើងថ្នាក់ ១ថ្នាក់ជាស្វ័យប្រវត្តិ តាមវេនជ្រើសរើស។

**មាត្រា ១៥.-**

មន្ត្រីសុខាភិបាលបឋម ត្រូវដាក់ឱ្យចូលនិវត្តន៍ ពេលដល់អាយុ ៥៨ ឆ្នាំ ។

ការដាក់អោយចូលនិវត្តន៍ ត្រូវសំរេចដោយប្រកាសរបស់ក្រសួងសុខាភិបាល ។ ស.រ.

# ជំពូកទី ៩

## អន្តរប្បញ្ញត្តិ

**មាត្រា ១៦.-**

ចំនួនដំបូងនៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលបឋម ត្រូវកសាងចេញពីសមាហរណកម្មមន្ត្រីរាជការ ដែលបច្ចុប្បន្ន កំពុងបំពេញមុខងារនិងមុខតំណែងពិតប្រាកដរបស់ក្របខ័ណ្ឌ ក្នុងវិស័យសុខាភិបាលនៅរដ្ឋបាលកណ្តាល និង ខេត្ត ក្រុង របស់ក្រសួង ស្ថាប័នរដ្ឋ ហើយដែលមានសញ្ញាប័ត្រណាមួយ ដូចមានចែងក្នុងមាត្រា៦ នៃព្រះរាជក្រឹត្យនេះ ។

**មាត្រា ១៧.-**

មន្ត្រីសុខាភិបាលបឋម ដែលបានតែងតាំងរួចហើយក្នុងមុខតំណែងគ្រប់គ្រងណាមួយ ត្រូវអនុញ្ញាតឱ្យបន្តមុខតំណែងរបស់ខ្លួន លើកលែងតែមានការចាំបាច់ត្រូវផ្លាស់ប្តូរមុខតំណែង ដែលជាសមត្ថកិច្ចរបស់ក្រសួងសុខាភិបាល ។

# ជំពូកទី ១០

## អវសានប្បញ្ញត្តិ

**មាត្រា ១៨.-**

បទប្បញ្ញត្តិណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៩.-**

សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

**មាត្រា ២០.-**

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។ ស.រ.

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី២១ ខែមិថុនា ឆ្នាំ ២០០២

ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ

នរោត្តម សីហនុ

នស/រកត.០២.០៦.០០១៧៧

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

ព្រះមហាក្សត្រ សូមឡាយព្រះហស្តលេខា

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

លេខ: ១៤៧ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល